# កិច្ចព្រមព្រៀង

ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០២០ នៅក្រុមហ៊ុន **នីចធី អ៊ីភែរ៉ល (ខេមបូឌា) ខូអិលធីឌី** បានបើកកិច្ចប្រជុំមួយក្រោមអធិបតីភាពលោក Kim Pan Kon ជាតំណាងក្រុមហ៊ុន ស្តីពីការព្យួរកិច្ចសន្យាការងារមួយរយៈដោយមូលហេតុផលិតផលដែលផលិតរួចហើយមិនអាចនាំចេញបាន ធ្វើឲ្យប៉ះពាល់ដល់សង្វាក់ផលិតកម្មមិនអាចដំណើរការបានពេញលេញក្នុងរយៈ ០២ ខែ។

សមាសភាពចូលរួម៖

1- ភាគីតំណាងរោងចក្រ

- លោក Kim Pan Kon តំណាងនាយករោងចក្រ
- លោក យី ស្រ៊ុ ជាប្រធានរដ្ឋបាល និងជាអ្នកកត់ត្រា

2- ភាគីតំណាងកម្មករនិយោជិត

- លោកស្រី ឈន ស៊ីណាត
- លោក សុខ ប៊ុនធឿន
- លោក សយ ល័ក្ខ
- លោក ម៉ន ពិសិទ្ធ
- លោកស្រី ប៉ែន រតនា
- លោកស្រី ចាន់ ស្រស់
- លោក ជួន ចាន់ឆាយា
- លោក ឈិន សុខៃ
- លោក ស រក្សា

ក្រោយពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក ភាគីទាំងពីរបានឈានដល់កិច្ចព្រមព្រៀងដូចខាងក្រោម ៖

1- ក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ២៧ នាក់បន្ថែម ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៨៧១ នាក់ ក្នុងរយៈពេល ០២ ខែ ដោយគិតចាប់ពីថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០២០។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
និច-ធី អ៊ីភែរ៉ល (ខេមបូឌា)
NEX-T APPAREL (CAMBODIA) Co., Ltd.
ក្រុងភ្នំពេញ

2- ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះខាងតំណាងកម្មករទាំងអស់បានឯកភាពគ្នាព្រមទទួលយកប្រាក់ឧបត្ថម្ភដែលក្រុមហ៊ុនផ្តល់ជូន៣០ដុល្លាអាមេរិកនិងប្រាក់ឧបត្ថម្ភដែលរដ្ឋាភិបាលផ្តល់ជូន៤០ដុល្លាអាមេរិក ក្នុងមួយខែ ដោយយោងទៅតាមសេចក្តីណែនាំស្តីពីការព្យួរកិច្ចសន្យាការងារលេខៈ ០៤៥/២០ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

3- ក្រុមហ៊ុនបើកប្រាក់ឧបត្ថម្ភចំនួន ៣០ដុល្លាអាមេរិក មួយខែម្តង នៅរៀងរាល់ថ្ងៃទី ៣០ នៃខែមិថុនា និងខែកក្កដា ឆ្នាំ២០២០។

4- ចប់ការព្យួរការងារកម្មករនិយោជិត ត្រូវមកចូលធ្វើការនៅកន្លែងដើមវិញ តាមតួនាទីភារកិច្ចរបស់ខ្លួន។

ការប្រជុំនេះចប់សព្វគ្រប់នៅវេលាម៉ោង១៥:៥០នាទី នាថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០២០ ដដែលក្រោមបរិយាកាសរីករាយ។

ថ្ងៃពុធ ៧ រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០២០

បានឃើញនឹងឯកភាព

តំណាងនាយកក្រុមហ៊ុន

NEX-T APPAREL (CAMBODIA) Co., Ltd.

Kim Pan Kon

អ្នកកត់ត្រា

យី ស្រ៊ី

បានឃើញនឹងឯកភាព

តំណាងកម្មករ

ឈន ស៊ីណាត　　សុខ ប៊ុនធឿន　　សយ ល័ក្ខ

ម៉ន ពិសិទ្ធ　　ប៉ែន រតនា　　ចាន់ ស្រស់

ជួន ចាន់ឆាយ៉ា　　ឈិន សុខៃ　　ស រក្សា